សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
E-Services for Business

# ព្រឹត្តិបត្រប្រចាំឆ្នាំ ២០២៤

## នៃលេខាធិការដ្ឋានក្រុមការងារ
## អន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

# មាតិកា


សាររបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ........................................០១

វឌ្ឍនភាពការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច........................................០៤

សេវាសាធារណៈដែលត្រូវបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន........................................០៦

វឌ្ឍនភាពការងារក្នុងឆ្នាំ ២០២៤........................................១០

របាយការណ៍ស្ថិតិ........................................១៥

កម្មវិធីផ្សព្វផ្សាយ........................................២១

ថ្នាលធុរកិច្ច - business.gov.kh........................................៤១

ព្រឹត្តិការណ៍សំខាន់ៗ........................................៤៣

# សាររបស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កម្ពុជាបាន និង កំពុងធ្វើទំនើបកម្មជាបន្តបន្ទាប់ ក្នុងការផ្តល់សេវាសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អស់រយៈពេលជាង ១០ ឆ្នាំ មកហើយ ដើម្បីឆ្លើយ-តបនឹងការវិវត្តន៍ឥតឈប់ឈរ និង឴ ឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ក្នុងគោល-បំណងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជាពិសេសសេវាពាក់ព័ន្ធនឹងការធ្វើធុរកិច្ច សំដៅលើកកម្ពស់បរិយាកាសនៃការធ្វើធុរកិច្ច និង បង្កើនភាពប្រកួតប្រជែងនៅកម្ពុជា។ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បន្តបេសកកម្មយ៉ាងមោះមុតលើការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថល តាមរយៈការដាក់ចេញ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**" ដោយយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពស្ថាប័ន និង អភិបាលកិច្ច ដើម្បីសម្រេចបាននូវរដ្ឋបាលសាធារណៈទំនើប មានសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត, និង ស្អាតស្អំ តាមរយៈការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ ជារួម និង ជាពិសេស សេវាសាធារណៈគាំទ្រដល់ធុរកិច្ច។

រាជរដ្ឋាភិបាលបានដាក់ដំណើរការ "**ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន**" ចាប់តាំងពីខែ មិថុនា ឆ្នាំ ២០២០ មក ដោយបានសម្រួលនីតិវិធីនៃការចុះបញ្ជីអាជីវកម្មឱ្យកាន់តែប្រសើរ, បានកាត់បន្ថយកម្រៃសេវាឱ្យស្ថិតក្នុងកម្រិតសមរម្យ, និង បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទាំង-ស្រុង ជាមធ្យោបាយផ្តល់ និង ទទួលសេវា។ ក្នុងរយៈពេលជិត ៥ ឆ្នាំ នេះ, ដំណើរការនៃការងាររៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន បានពង្រីកការដ្ឋានរហូតដល់ ៣ ដំណាក់កាល ចាប់ពីការចុះបញ្ជីអាជីវកម្មជាកញ្ចប់ (Single Portal) នៅដំណាក់កាលទី ១ ឈានដល់ ដំណាក់កាលទី ២, ទី ៣ និង ដំណាក់កាលបន្តបន្ទាប់ ដែលគ្របដណ្តប់បន្ថែមដល់ការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាត ផ្អែកលើសកម្មភាពអាជីវកម្មតាមវិស័យនានាផងដែរ ដែលមានការចូលរួមពីក្រសួង ស្ថាប័ន ចំនួន ២០ និង បានបញ្ចូលសេវាសាធារណៈចំនួន ៣៣ គិតមកដល់ពេលបច្ចុប្បន្ន ក្រោមការសម្របសម្រួលរបស់ក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន។ គិតត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ ២០២៤, ក្រុមហ៊ុន សហគ្រាស សរុបប្រមាណ ៤២ ពាន់ ទទួលបានការអនុម័តចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធ Single Portal ដោយមានដើមទុនវិនិយោគសរុបប្រមាណ ១៥,៦ ប៊ីលានដុល្លារអាម៉េរិក និង អាជ្ញាបណ្ណ

លិខិតអនុញ្ញាត និង វិញ្ញាបនបត្រតាមវិស័យ ចំនួនប្រមាណ ២៨ ៣ន់ ត្រូវបានអនុម័តដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ននីមួយៗ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលរួម ក្រោមក្របខ័ណ្ឌអន្តរប្រតិបត្តិការនៃការផ្លាស់ប្តូរទិន្នន័យ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ន តាមថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)។

នៅចុងឆ្នាំ ២០២៣, ក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ត្រូវបានកែសម្រួលសមាសភាព និង ប្តូរឈ្មោះទៅជា ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីបន្តដឹកនាំ និង សម្រួលការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ក្នុងគោលដៅផ្តល់សេវាដែលមានតម្រូវការស្នើសុំញឹកញាប់ និង មានហានិភ័យទាប តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលតែមួយ។ ការកែលម្អការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ជាការងារដែលត្រូវធ្វើជាប្រចាំ និង ត្រួតពិនិត្យឡើងវិញជារង្វិលជុំនូវដំណើរការកិច្ចការមួយចំនួន រួមមាន ៖ ការពិនិត្យ និង កែសម្រួលបទប្បញ្ញត្តិ, ការរៀបចំយន្តការផ្តល់សេវា, ការប្រើប្រាស់ប្រព័ន្ធឌីជីថលជាទម្រង់សមាហរណកម្មនៃការប្រព័ន្ធអេកូឡូស៊ីឌីជីថលតែមួយ, និង ការទទួលមតិយោបល់ពីពលរដ្ឋ និង ធុរជន។ មុនពេលរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យារបស់ក្រសួង ស្ថាប័ន រៀបចំឡើងក្នុងទម្រង់ជាពាក់កណ្តាលអនឡាញ ឬ អនឡាញពេញលេញដែរ ប៉ុន្តែរៀបចំជាប្រព័ន្ធឈរតែឯង ខ្វះយន្តការអន្តរប្រតិបត្តិការជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត ដែលមិនអាចទាញអស់នូវសក្តានុពលពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលនីតិវិធីនៃការផ្តល់សេវាជាអតិបរមា។ ទោះបីរាជរដ្ឋាភិបាលមានយន្តការនៃការចុះបញ្ជីអាជីវកម្មរួម តាមប្រព័ន្ធអេកូឡូស៊ីឌីជីថលតែមួយ, ចំនួនសេវាដែលបានផ្តល់តាមយន្តការនេះមានប្រមាណតែ ៤,៦% នៃសេវាសម្រាប់ធុរកិច្ចទាំងមូលតែប៉ុណ្ណោះ ដែលទាមទារនូវការរៀបចំយុទ្ធសាស្ត្រមុតស្រួចមួយ សម្រាប់អនុវត្តដោយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជា "**ឧទភាពនៃប្រព័ន្ធតួអង្គតែមួយ**"។

ដើម្បីបង្កើនល្បឿននៃការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ពង្រឹងបន្ថែមនូវវិធានការអន្តរាគមន៍នៃការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ "**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**" ដោយមានចក្ខុវិស័យ "**ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និង តម្លាភាពព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង**" និង មានគោលបំណង "**បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង លើកកម្ពស់ការបំពេញអនុលោមភាព**"។ លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រនេះនឹងបង្កើតបានជា "**ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច**" ដែលម្យ៉ាងនឹងធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃការផ្តល់សេវាសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ដែលជាសមាជិកនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលនេះ ធ្វើអន្តរសកម្ម និង ផ្តល់ការផ្ទៀងផ្ទាត់ទិន្នន័យឱ្យគ្នាទៅវិញទៅមក សំដៅកាត់បន្ថយការបំពេញទិន្នន័យដដែលៗ ក្នុងការស្នើសុំសេវា, និង ម្យ៉ាងទៀតនឹងបង្កើតឱ្យមានប្រព័ន្ធទិន្នន័យគោលបន្ថែមទៀត បម្រើដល់តម្រូវការរបស់វិស័យឯកជន សំដៅជំរុញនវានុវត្តន៍ក្នុងអាជីវកម្ម។ ជាក់ស្តែង, ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (e-KYC) របស់ក្រសួងមហាផ្ទៃ ត្រូវបានដាក់ដំណើរការសាកល្បងអស់រយៈពេលជាង ២ ឆ្នាំ និង កំពុងប្រែក្លាយជាថ្នាលឌីជីថលសម្រាប់ប្រមូលចំណូល ដោយមានសមាជិកពីវិស័យឯកជនចំនួន ៣៥ គិតត្រឹមចុងឆ្នាំ ២០២៤ កំពុងប្រើប្រាស់សេវានេះ ក្នុងទំហំជាមធ្យមប្រហែល ១ លាន ប្រតិបត្តិការ ក្នុងមួយខែ។ ដូចគ្នាដែរ, ប្រព័ន្ធសម្គាល់អត្តសញ្ញាណសហគ្រាសឌីជីថល (e-KYB) ដែលកើតចេញពីបង្គុំនៃប្រព័ន្ធចុះបញ្ជីអាជីវកម្មរបស់ក្រសួងពាណិជ្ជកម្ម, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ត្រូវបានដាក់ដំណើរការសាកល្បងនៅក្នុងខែ កញ្ញា ឆ្នាំ ២០២៤ នេះដែរ។

សមិទ្ធផលទាំងនេះ សរបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាល និង ការចូលរួមយ៉ាងសកម្មរបស់ក្រសួង ស្ថាប័ន ដែលបានធ្វើការប្រទាក់ក្រឡាគ្នា និង ផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធ ដើម្បីកែសម្រួលបរិយាកាសនៃការធ្វើធុរកិច្ច និង ការវិនិយោគឱ្យកាន់តែប្រសើរ សំដៅលើកកម្ពស់ភាពប្រកួតប្រជែងក្នុងទីផ្សារកម្ពុជា និង រួមចំណែក

ដល់កំណើន និង និរន្តរភាពនៃសកម្មភាពសេដ្ឋកិច្ច និង សង្គម តាមរយៈការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ ជាបន្តបន្ទាប់។

ព្រឹត្តិបត្រប្រចាំឆ្នាំ ២០២៤ របស់លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិក ត្រូវបានរៀបចំឡើង ដើម្បីជាសក្ខីកម្មរំលេចឱ្យឃើញនូវសមិទ្ធផលការងារដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំផ្តួចផ្តើមបង្កើតឡើង និង បន្តពង្រឹង និង ពង្រីកការងារអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ជាពិសេសសមិទ្ធផលការងារក្នុងឆ្នាំ ២០២៤ កន្លងមក។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល, ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈនយោបាយមុតស្រួច និង ចក្ខុវិស័យវែងឆ្ងាយ ដែលតែងតែបាន និង បន្តតម្រង់ទិសឱ្យក្រសួង ស្ថាប័នរៀបចំយន្តការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និង ធុរជន។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ផងដែរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលចូលរួមឱ្យរាជរដ្ឋាភិបាលសម្រេចនូវសមិទ្ធផលដូចបានរៀបរាប់ខាងលើ គួរជាទីមោទនៈ, ហើយក្នុងឆ្នាំ ២០២៥ នេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ចូលរួមសហការឱ្យកាន់តែស្អិតរមួតបន្ថែមទៀត និង អនុវត្តនូវវិធានការគន្លឹះក្នុងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨ ឱ្យមានប្រសិទ្ធភាព សំដៅបង្កើនឧត្តមភាពនៃការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចនៅកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែពិសាខ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និង ជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# វឌ្ឍនភាពការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

**មីនា ២០១៩**

វិស័យឯកជនបានលើកឡើងនូវបញ្ហាប្រឈមពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម នៅក្នុងវេទិការាជរដ្ឋាភិបាល វិស័យឯកជន លើកទី ១៨

**ឧសភា ២០១៩**

បង្កើតក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform)

**កក្កដា ២០១៩**

បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង (បទប្បញ្ញត្តិ និង បច្ចេកវិទ្យាព័ត៌មាន) រៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform)

**មិថុនា ២០២០**

ដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១

**កញ្ញា ២០២១**

ដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ២

**ឧសភា ២០២៣**

បញ្ចូលមុខងារសំខាន់ៗចំនួន ៣ នៅលើ Single Portal
- មុខងារចុះបញ្ជីបំពេញបន្ថែមកាតព្វកិច្ច
- មុខងារស្នើសុំកែតម្រូវព័ត៌មានដែលមិនប៉ះពាល់ដល់ទ្រង់ទ្រាយក្រុមហ៊ុន សហគ្រាស និង កម្រៃសេវាដែលបានបង់ហើយ
- មុខងារស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងព័ត៌មានក្រុមហ៊ុនសហគ្រាស

# វឌ្ឍនភាពការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

**មិថុនា ២០២៣**

ដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធ
ចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យា
ព័ត៌មាន ដំណាក់កាលទី ៣

**ធ្នូ ២០២៣**

ផ្ទេរបច្ចុប្បន្នកម្មពីក្រុមការងារអន្តរក្រសួងរៀបចំ
ការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន
(IT Platform) ទៅជា ក្រុមការងារអន្តរក្រសួង
រៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

**មករា ២០២៤**

បន្ថែមមុខងារចុះបញ្ជីកែប្រែព័ត៌មាន
ក្រុមហ៊ុន សហគ្រាស ចំនួន ៥ មុខងារ
ក្នុងដំណាក់កាលទី ១

**កុម្ភៈ ២០២៤**

រៀបចំកិច្ចប្រជុំអន្តរក្រសួងលើកទី ១
នៃក្រុមការងារអន្តរក្រសួងរៀបចំសេវា
អេឡិចត្រូនិកសម្រាប់ធុរកិច្ច

**មិថុនា ២០២៤**

ចាប់ផ្តើមគិតគូររៀបចំយុទ្ធ-
សាស្រ្តស្តីពីការអភិវឌ្ឍសេវា
អេឡិចត្រូនិកសម្រាប់ធុរកិច្ច

**វិច្ឆិកា ២០២៤**

រៀបចំកិច្ចប្រជុំអន្តរក្រសួងលើកទី ២ នៃ
ក្រុមការងារអន្តរក្រសួងរៀបចំសេវា
អេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីពិនិត្យ និង
ផ្តល់យោបល់ លើយុទ្ធសាស្រ្តស្តីពី
ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

បន្ថែមមុខងារចុះបញ្ជី
កែប្រែព័ត៌មាន
ក្រុមហ៊ុន សហគ្រាស
ចំនួន ៦ មុខងារ
ក្នុងដំណាក់កាលទី ២

# សេវាសាធារណៈដែលត្រូវបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

## ការចុះបញ្ជីអាជីវកម្មជាកញ្ចប់

### ក្រសួងពាណិជ្ជកម្ម

- ការបម្រុងទុកនាមករណ៍
- ការចុះបញ្ជីពាណិជ្ជកម្ម

### អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ការចុះបញ្ជីពន្ធដារ

### ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ការធ្វើសេចក្តីប្រកាស ជូនដំណឹងសហគ្រាស

### បេឡាជាតិសន្តិសុខសង្គម

- ការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន

### ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ការស្នើសុំប្រកាសបង្កើត សហគ្រាស ធុនតូចនិងមធ្យម និង សហគ្រាសធុនមីក្រូ (សិប្បកម្ម)

# សេវាសាធារណៈដែលត្រូវបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

## សេវាស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាត

### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- ការស្នើសុំចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

### ក្រសួងទេសចរណ៍

- ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍
- ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និង សេវាស្នាក់នៅទេសចរណ៍
- ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍

### ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- ការស្នើសុំការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាទូរគមនាគមន៍
- ការស្នើសុំការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យប្រៃសណីយ៍

### និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

- ការស្នើសុំអាជ្ញាបណ្ណអាជីវកម្មបញ្ចាំ
- ការស្នើសុំអាជ្ញាបណ្ណអាជីវកម្មប្រាតិភោគដោយអនុប្បទាន
- ការស្នើសុំអាជ្ញាបណ្ណ និង/ឬ វិញ្ញាបនបត្រវិជ្ជាជីវៈសម្រាប់អាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ



# សេវាសាធារណៈដែលត្រូវបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

## សេវាស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាត

### ក្រសួងពាណិជ្ជកម្ម

ការស្នើសុំអាជ្ញាបណ្ណ និង/ឬ
លិខិតអនុញ្ញាតធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក

### ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹម
ឬ បង្កាត់ពូជសត្វ (ខ្នាតមធ្យម និង ខ្នាតធំ)

### ធនាគារជាតិនៃកម្ពុជា

ការស្នើសុំអាជ្ញាបណ្ណ និង/ឬ
លិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់

### និយ័តករធានារ៉ាប់រងកម្ពុជា

ការស្នើសុំចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល

### និយ័តករគណនេយ្យ និងសវនកម្ម

ការស្នើសុំអាជ្ញាបណ្ណ និង/ឬ
លិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម

### អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ការស្នើសុំចុះបញ្ជីអ្នកទទួលការសាងសង់

# សេវាសាធារណៈដែលត្រូវបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

## សេវាផ្សេងៗពាក់ព័ន្ធនឹងការធ្វើធុរកិច្ច

### និយ័តករទូរគមនាគមន៍កម្ពុជានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- សេវាស្នើសុំចុះឈ្មោះដែនជាតិ ".kh"
- សេវាស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និង គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតការនាំចូល គ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និង គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន
- សេវាស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍
- សេវាស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង ចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍

### ក្រសួងមហាផ្ទៃ

សេវាផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណកម្មសម្រាប់ការចូលប្រើប្រាស់ជតថល

### ក្រសួងយុត្តិធម៌

សេវាស្នើសុំព្រឹត្តិបត្រថ្កោលទោស

### មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

សេវាស្នើសុំចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)

## កិច្ចសហប្រតិបត្តិការ ជាមួយក្រសួង ស្ថាប័ន ដែលបានបញ្ចូលសេវាបន្ថែម

មានចំនួន **១៣**

# វឌ្ឍនភាពការងារក្នុងឆ្នាំ ២០២៤

## កិច្ចសហប្រតិបត្តិការ ជាមួយក្រសួង ស្ថាប័ន ដែលបានបញ្ចូលសេវាបន្ថែម

### អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

- សេវាស្នើសុំចុះបញ្ជីអ្នកទទួលការសាងសង់

### ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- សេវាស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬ បង្កាត់ពូជសត្វ

### ធនាគារជាតិនៃកម្ពុជា

- សេវាស្នើសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មប្តូរប្រាក់

### ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- សេវាពិនិត្យព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក
- សេវាសំណង់តាមប្រព័ន្ធអេឡិចត្រូនិក

### ក្រសួងព័ត៌មាន

- សេវាផ្តល់បណ្ណសារព័ត៌មាន (ជារូបវន្តបុគ្គល)

### និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- សេវាស្នើសុំអាជ្ញាបណ្ណ និង/ឬ វិញ្ញាបនបត្រវិជ្ជាជីវៈសម្រាប់អាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ

# វឌ្ឍនភាពការងារក្នុងឆ្នាំ ២០២៤

## កិច្ចសហប្រតិបត្តិការ ជាមួយក្រសួង ស្ថាប័ន ដែលបានបញ្ចូលសេវាបន្ថែម

### និយ័តករទូរគមនាគមន៍កម្ពុជានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- សេវាស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និង គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតការនាំចូលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន
- សេវាស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញខ្សែកាប្លិ៍ទូរគមនាគមន៍
- សេវាស្នើសុំលិខិតអនុញ្ញាតថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្ដាញខ្សែកាប្លិ៍ទូរគមនាគមន៍
- សេវាស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង ចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និង គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

## មុខងារថ្មីដែលបានបញ្ចូលក្នុងប្រព័ន្ធ Single Portal ក្នុងឆ្នាំ ២០២៤

មានចំនួន ១១

## មុខងារថ្មីដែលបានបញ្ចូលក្នុងប្រព័ន្ធ Single Portal ក្នុងឆ្នាំ ២០២៤

### មុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន សហគ្រាស ដំណាក់កាលទី ១

- មុខងារកែប្រែសកម្មភាពអាជីវកម្ម
- មុខងារកែប្រែព័ត៌មានលម្អិតអាសយដ្ឋានទីស្នាក់ការចុះបញ្ជី
- មុខងារតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ
- មុខងារកែប្រែលក្ខន្តិកៈក្រុមហ៊ុន
- មុខងារកែប្រែព័ត៌មានគណនីធនាគារ

### មុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន សហគ្រាស ដំណាក់កាលទី ២

- មុខងារកែប្រែនាមករណ៍ក្រុមហ៊ុន សហគ្រាស
- មុខងារកែប្រែព័ត៌មានលម្អិតអភិបាល
- មុខងារកែប្រែព័ត៌មានលម្អិតម្ចាស់សហគ្រាស
- មុខងារកែប្រែព័ត៌មានលម្អិតម្ចាស់ភាគហ៊ុន
- មុខងារកែប្រែសមាសភាពអ្នកគ្រប់គ្រងសាខា ឬ ការិយាល័យតំណាងក្រុមហ៊ុនបរទេស
- មុខងារបញ្ឈប់អាជីវកម្មជាស្ថាពរសម្រាប់ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម



## វឌ្ឍនភាពការងារជាតួលេខ ក្នុងឆ្នាំ ២០២៤

| | |
|---|---|
| ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារអន្តរក្រសួង និង ដៃគូពាក់ព័ន្ធផ្សេងៗ | បានចូលរួម និង បានរៀបចំ វគ្គបណ្តុះបណ្តាល និង សិក្ខាសាលា |
| **>៤០ ដង** | **៤៣ ដង** |
| រយៈពេលដែលបានគាំទ្រតាមទូរស័ព្ទ | ចំនួនករណីដែលបានគាំទ្រ |
| **~៥,៥៦០ នាទី** | **៦,៦៩៥ ករណី** |
| ចំនួនដៃគូធនាគារទូទាត់ប្រាក់ | ចំនួនសារព័ត៌មានដែលបានផ្សព្វផ្សាយ |
| **៣ ធនាគារ** | **២៣ ដង** |

## ការចុះបញ្ជីអាជីវកម្មជាកញ្ចប់

### ក្រុមហ៊ុន សហគ្រាសដែលចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

រួមមាន ការចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ការប្រកាសសេចក្តីជូនដំណឹងបើកសហគ្រាស នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការចុះបញ្ជិកាក្រុមហ៊ុន សហគ្រាស នៅបេឡាជាតិសន្តិសុខសង្គម។



## ដើមទុនវិនិយោគសរុប ដែលទទួលបានពីប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

គិតចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

# ~១៥,៦២

## ប៊ីលានដុល្លារអាមេរិក

# របាយការណ៍ស្ថិតិ

## ការចុះបញ្ជីអាជីវកម្មជាកញ្ចប់

កម្មវត្ថុអាជីវកម្មទាំង ៥ ដែលមានដើមទុនវិនិយោគចុះបញ្ជីច្រើនជាងគេនៃឆ្នាំ ២០២៣

**~៣,៧៦ ប៊ីលានដុល្លារអាមេរិក**



## ការចុះបញ្ជីអាជីវកម្មជាកញ្ចប់

### កម្មវត្ថុអាជីវកម្មទាំង ៥ ដែលមានដើមទុនវិនិយោគចុះបញ្ជីច្រើនជាងគេនៃឆ្នាំ ២០២៤

## ~៦ ប៊ីលានដុល្លារអាមេរិក

(↑~៦០% ប្រៀបធៀបឆ្នាំ ២០២៣)




- ការដាំដុះដំណាំអាយុកាលខ្លី
- កម្មន្តសាល ដែកមូលដ្ឋាន និង ដែកថែប
- សកម្មភាពសេវាកម្មស្នាក់នៅ
- ការផលិត ការបញ្ជូន និង ការចែកចាយថាមពលអគ្គីសនី
- សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬ ជួលពីគេ
- ផ្សេងៗ

## ការស្នើសុំអាជ្ញាបណ្ណ, វិញ្ញាបនបត្រ និង លិខិតអនុញ្ញាត

### ក្រុមហ៊ុន សហគ្រាសដែលស្នើសុំអាជ្ញាបណ្ណ, វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតជំនាញ

ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ, បេឡាជាតិសន្តិសុខសង្គម និង និយ័តករធានារ៉ាប់រងកម្ពុជា



## សៀវភៅមគ្គុទ្ទេសក៍ថ្មីៗ

# មានចំនួន ៦

## សៀវភៅមគ្គុទ្ទេសក៍ថ្មីៗ

- សៀវភៅមគ្គុទ្ទេសក៍ របៀបស្នើសុំចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន សហគ្រាស ដំណាក់កាលទី ១
- សៀវភៅមគ្គុទ្ទេសក៍ ការស្នើសុំប្រកាសបង្កើត ប្រកាសបង្កើតសហគ្រាសធុនតូចនិងមធ្យម និង សហគ្រាសធុនមីក្រូ (សិប្បកម្ម)
- សៀវភៅមគ្គុទ្ទេសក៍ ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណទេសចរណ៍
- សៀវភៅមគ្គុទ្ទេសក៍ សម្រាប់ការស្នើសុំអាជ្ញាបណ្ណពី និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- សៀវភៅមគ្គុទ្ទេសក៍ ដំណើរការស្នើសុំសេវាសាធារណៈឌីជីថលរបស់និយ័តករទូគមនាគមន៍កម្ពុជា
- សៀវភៅមគ្គុទ្ទេសក៍ សម្រាប់ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ ពីធនាគារជាតិនៃកម្ពុជា
- សៀវភៅមគ្គុទ្ទេសក៍ សម្រាប់ស្នើសុំសេវាសាធារណៈ ផ្តល់ដោយរដ្ឋបាលថ្នាក់កណ្តាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សៀវភៅមគ្គុទ្ទេសក៍ ស្តីពីការស្នើសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ
- សៀវភៅមគ្គុទ្ទេសក៍ ស្តីពីការស្នើសុំវិញ្ញាបនបត្រអ្នកទទួលការសាងសង់







## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ

# មានចំនួន ៦

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ក្នុងបរិបទនៃបរិវត្តកម្មឌីជីថលការងារទាំងអស់នោះយើងអាចធ្វើតាមអនឡាញបាន មួយផ្នែកយើងធ្វើតាម Single Window ដែលយើងធ្វើជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា តែផ្នែកដែលមិនពាក់ព័ន្ធជាមួយការនាំចេញ-នាំចូល សេវាសាធារណៈទាំងអស់នោះនឹងធ្វើនៅលើ Platform មួយទៀត ដែលយើងសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំអោយមានជាសេវាសាធារណៈ  តាមរយៈថ្នាល CamDX ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដាក់ឱ្យគាំទ្របន្ថែម សម្រាប់ក្រសួង ស្ថាប័នផ្សេងៗ។"

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

"ពេលនេះប្រព័ន្ធ CamDX ជាប្រព័ន្ធប្រទាក់ក្រឡាគ្នា ដែលអនុញ្ញាតនៅពេលចុះបញ្ជី ជាក់ស្តែង ពេលយើងចុះបញ្ជីក្រុមហ៊ុនពីដើមទីទៅ យើងនឹងទទួលបានសេវាកម្មដល់ទៅបីតាមពិតដល់ប្រាំផងក្នុងពេលតែមួយ ដែលចេញពីប្រព័ន្ធ CamDX នេះ ក្នុងនោះមានន័យថាអាចចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មជាមួយក្រុមហ៊ុន ហើយក៏ទទួលបានការចុះបញ្ជីពន្ធប៉ាតង់ជាមួយខាងអគ្គនាយកដ្ឋានពន្ធដារ ហើយការចុះបញ្ជិការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ។"

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

"ខ្ញុំសូមវាយតម្លៃខ្ពស់តាមថ្នាល CamDX ហើយនិងការរៀបចំ កន្លងមកដែលរាជរដ្ឋាភិបាលបានបង្កើតនូវ Platform ដ៏មានសារៈសំខាន់នេះ ធ្វើយ៉ាងណាឱ្យយើងទាំងអស់គ្នា ក្រសួង ស្ថាប័នទាំងអស់ ដែលពីមុនមានរបៀបរបបការងារ ដែលនៅដាច់ដោយឡែកពីគ្នា បានមកជុំគ្នា ហើយបានមកផ្លាស់ប្តូរទិន្នន័យគ្នា ហើយបង្កនូវភាពងាយស្រួលដល់ធុរជន ដល់បងប្អូនដែលលោកប្រកបរបរទទួលទាន ចំណុចសំខាន់ណាស់។"

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ការចូលរួមរបស់ក្រសួងជាមួយនឹងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មានដែលយើងហៅកាត់ថា CamDX នេះ គឺពិតជាជួយដល់ក្រសួងច្រើន បន្ថែមពីលើការជួយទៅដល់បុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើធុរកិច្ច គឺក្រសួង ស្ថាប័នដែលចូលរួមនៅក្នុងការអនុវត្តប្រព័ន្ធនេះ ក៏ទទួលបាននូវអត្ថប្រយោជន៍ជាច្រើន។"

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ខ្ញុំសង្កេតឃើញថា ការចុះបញ្ជីតាមថ្នាលនេះ គឺឃើញថាមានប្រសិទ្ធភាពល្អ ហើយមានភាពងាយស្រួលចំពោះអាជីវកម្ម ដែលគេចង់មកបើកអាជីវកម្ម និង វិនិយោគ។ ខ្ញុំជំរុញឱ្យមានការលើកទឹកចិត្តបន្ថែមទៀតចំពោះការអភិវឌ្ឍទៅលើថ្នាល CamDX ហ្នឹង នៅក្នុងថ្នាលនេះពង្រីកវិសាលភាពថែមទៀត។"

## កិច្ចសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ



### ឯកឧត្តមបណ្ឌិត គង់ ម៉ារី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"យើងរំពឹងថា ត្រឹមដំណាច់អាណត្តិការងារទី៧នៃរាជរដ្ឋាភិបាល សេវាជាច្រើនរបស់រាជរដ្ឋាភិបាលសម្រាប់ធុរកិច្ចនឹងអាចត្រូវបានធ្វើឌីជីថលូបនីយកម្ម គឺអាចស្នើសុំតាមប្រព័ន្ធអនឡាញបាន ដែលស្របជាមួយនឹងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលយើងធ្វើម៉េចពង្រឹងសេវាអេឡិចត្រូនិកពង្រឹងធុរកិច្ចឌីជីថលនេះ ឱ្យកាន់តែរឹងមាំ និង កាន់តែមានវិសាលភាពគ្របដណ្តប់ឱ្យបានទូលំទូលាយ។"

## កិច្ចសម្ភាសន៍ជាមួយមន្ត្រីជំនាញ




### កម្មវិធីជជែកវែកញែក
### "ពីនេះពីនោះរឿងស្នើសុំធ្វើអាជីវកម្ម" វគ្គរកាលទី២

លោកអ្នកអាចចូលទស្សនាវីដេអូជជែកវែកញែក កាលពីរដូវកាលទី ២ ទាំង ៩ ប្រធានបទ នៅក្នុងទំព័រហ្វេសប៊ុកផ្លូវការ និង/ឬឆាណែលយូធូបរបស់យើង។

**Online Business Registration Service**

សូមចូលរួមទស្សនាទាំងអស់គ្នាដើម្បីទទួលបានគន្លឹះសំខាន់ៗ និង ព័ត៌មានទូទៅទាក់ទងនឹងសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

## កិច្ចសម្ភាសន៍ជាមួយមន្ត្រីជំនាញ

# មានចំនួន ៥

## កិច្ចសម្ភាសន៍ជាមួយមន្ត្រីជំនាញ

### ប្រធានបទ
### កម្មវិធីផ្ទែករកៃញែក "ពីនេះពីនោះរឿងស្នើសុំធ្វើអាជីវកម្ម" វគ្គវកាលទី ២

១. ការចុះបញ្ជីអាជីវកម្ម ក្នុងបរិបទទីផ្សារដែលមានការប្រកួតប្រជែងខ្ពស់

២. ការស្នើសុំអាជ្ញាបណ្ណតាមវិស័យ ៖ វិស័យទេសចរណ៍

៣. ការស្នើសុំអាជ្ញាបណ្ណតាមវិស័យ ៖ វិស័យកម្មន្តសាល (សហគ្រាសធុនតូច និង មធ្យម និង សិប្បកម្ម)

៤. ការស្នើសុំអាជ្ញាបណ្ណតាមវិស័យ ៖ វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)

៥. ការស្នើសុំអាជ្ញាបណ្ណតាមវិស័យ ៖ ការប្រកបអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

៦. ការស្នើសុំអាជ្ញាបណ្ណតាមវិស័យ ៖ ការប្រកបអាជីវកម្មគណនេយ្យ និងសវនកម្ម

៧. របៀបបំពេញព័ត៌មានស្នើសុំសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

៨. អត្ថប្រយោជន៍និយោជិតពីបេឡាជាតិសន្តិសុខសង្គម

៩. ព័ត៌មានទូទៅពាក់ព័ន្ធនឹងប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន និង មុខងារថ្មីៗ









## វីដេអូជំណើរសហគ្រិនភាពរបស់ធុរជន

# មានចំនួន ៥

## វីដេអូចំណើរសហគ្រិនភាពរបស់ធុរជន




បេប៊ី យូខេ (ខេមបូឌា)




ម៉េកឃីង ប្រជីធី អ៊ីហ្សី ឯ.ក




ភីត អេលីត ប៊ូទិក



អុកស៊ីជេន ខហ្វី




ប្រេស្ទី អ៊ីឡូយអិន ឯ.ក

## កិច្ចការបណ្តុះបណ្តាល និង សិក្ខាសាលាសំខាន់ៗ

មានចំនួន **៤៣**

# កម្មវិធីផ្សព្វផ្សាយ

## កិច្ចការបណ្តុះបណ្តាល និង សិក្ខាសាលាសំខាន់ៗ



### ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២៤

វគ្គបណ្តុះបណ្តាលជនបង្គោលស្តីពី "នីតិវិធីចុះបញ្ជីអាជីវកម្ម និង
ការស្នើសុំអាជ្ញាបណ្ណជំនាញតាមវិស័យ តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន" លើកទី ១

### ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២៤

វគ្គបណ្តុះបណ្តាលមន្ត្រី និង បុគ្គលិកផ្នែកគាំទ្រអ្នកប្រើប្រាស់ (User Suppport)
នៃប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន លើកទី ១

### ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២៤

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សហគ្រិនភាព និង ការចុះបញ្ជីអាជីវកម្ម
សម្រាប់ការត្រៀមខ្លួនរបស់សហគ្រិនវ័យក្មេង" សាកលវិទ្យាល័យជាតិបាត់ដំបង

### ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២៤

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សហគ្រិនភាព និង ការចុះបញ្ជីអាជីវកម្ម
សម្រាប់ការត្រៀមខ្លួនរបស់សហគ្រិនវ័យក្មេង"
សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ សៀមរាប

# កម្មវិធីផ្សព្វផ្សាយ

## កិច្ចការបណ្តុះបណ្តាល និង សិក្ខាសាលាសំខាន់ៗ

### ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៤

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សហគ្រិនភាព និង ការចុះបញ្ជីអាជីវកម្ម សម្រាប់ការត្រៀមខ្លួនរបស់សហគ្រិនវ័យក្មេង" សាកលវិទ្យាល័យវេស្ទើនកំពង់ចាម

### ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០២៤

វគ្គបណ្តុះបណ្តាលជនបង្គោលស្តីពី "នីតិវិធីចុះបញ្ជីអាជីវកម្ម និង ការស្នើសុំអាជ្ញាបណ្ណជំនាញតាមវិស័យ តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន" លើកទី ២

### ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២៤

វគ្គបណ្តុះបណ្តាលមន្ត្រី និង បុគ្គលិកផ្នែកគាំទ្រអ្នកប្រើប្រាស់ (User Suppport) នៃប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន លើកទី ២

### ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០២៤

សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "បទពិសោធន៍ចុះបញ្ជីអាជីវកម្ម តាមរយៈប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន"

### ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២៤

សិក្ខាសាលាពិគ្រោះយោបល់ ស្តីពី "សេចក្តីព្រាងយុទ្ធសាស្ត្រ ស្តីពី ការរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ២០២៥-២០២៨"

### ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០២៤

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការយកកម្រៃសេវាលើការផ្ទៀងផ្ទាត់ទិន្នន័យ អត្តសញ្ញាណបុគ្គល តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)"

# កម្មវិធីផ្សព្វផ្សាយ

## សំណួរប្រចាំសប្តាហ៍

ផ្សព្វផ្សាយចំណេះដឹងទូទៅដល់មហាជន មិនថាជាធុរជន ជាបុគ្គលិកធ្វើការ ឬ សិស្សានុសិស្ស សុទ្ធតែអាចយល់ជ្រាបពីការចុះបញ្ជីអាជីវកម្មនេះបាន ក្នុងទិដ្ឋភាពរីករាយ និង ទូលំទូលាយ។

| បានផ្សព្វផ្សាយចំនួន | មានអ្នកចូលរួមឆ្លើយសំណួរចំនួន | មានអ្នកឈ្នះរង្វាន់ចំនួន |
|---|---|---|
| ៤៤ សំណួរ | ៤៥៥ នាក់ | ៤៤ នាក់ |









## វីដេអូផ្សព្វផ្សាយ

មានចំនួន ៣១

# កម្មវិធីផ្សព្វផ្សាយ

## វីដេអូផ្សព្វផ្សាយ

ក្នុងគោលបំណងចែករំលែកព័ត៌មាន ចំណេះដឹង និង គន្លឹះផ្សេងៗ ទាក់ទងនឹងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា និង កម្មវិធីទូរស័ព្ទដៃ CamDigiKey។



















# ថ្នាលធុរកិច្ច - business.gov.kh

ថ្នាលធុរកិច្ច
business.gov.kh

ជាបណ្តុំព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលនៃសេវាសាធារណៈ ដែលពាក់ព័ន្ធនឹងការធ្វើធុរកិច្ចនៅកម្ពុជា។ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ថ្នាលធុរកិច្ចកម្ពុជា (business.gov.kh) ជាមជ្ឈមណ្ឌលព័ត៌មានកណ្តាលដែលធុរជន និង វិនិយោគិនក្នុង និង ក្រៅស្រុក អាចស្វែងរកបានយ៉ាងងាយស្រួល ប្រកបដោយទំនុកចិត្ត។



# ថ្នាលធុរកិច្ច - business.gov.kh

ថ្នាលធុរកិច្ចមានព័ត៌មានដូចជា ៖

១. ការចាប់ផ្តើមស្វែងយល់អំពីអាជីវកម្ម ដោយគ្រាន់តែប្រើពាក្យគន្លឹះនៃសកម្មភាពអាជីវកម្មរបស់លោកអ្នក

២. ការស្វែងយល់មុនការធ្វើធុរកិច្ច

៣. ការចាប់ផ្តើមធ្វើធុរកិច្ច

៤. ការប្រតិបត្តិការធ្វើធុរកិច្ច

៥. ការបិទធុរកិច្ច

៦. ព័ត៌មាន ស្ថិរភាពនយោបាយ, កំណើនសេដ្ឋកិច្ច និង សក្តានុពលនៃប្រទេសកម្ពុជា

៧. ស្វែងយល់អំពីស្ថិតិនៃការធ្វើធុរកិច្ច លើប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

៨. ស្វែងយល់អំពីសេវាអេឡិចត្រូនិកនានា ដែលពាក់ព័ន្ធនឹងការធ្វើធុរកិច្ច

៩. ទទួលបានបណ្តុំព័ត៌មានថ្មីៗពាក់ព័ន្ធនឹងការធ្វើធុរកិច្ច



## កិច្ចប្រជុំសំខាន់ៗ

### ចំនួននៃការចូលរួមកិច្ចប្រជុំជាមួយក្រុមការងារអន្តរក្រសួង និង ដៃគូពាក់ព័ន្ធផ្សេងៗ

# >៤០

## កិច្ចប្រជុំសំខាន់ៗ

| | |
|---|---|
| 19/02/24 | កិច្ចប្រជុំលើកទី ១ របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច |
| 25/04/24 | កិច្ចប្រជុំពិភាក្សា លើការអនុវត្តការងារចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Single Portal) នៅទីស្តីការក្រសួងពាណិជ្ជកម្ម |
| 28/06/24 | កិច្ចប្រជុំដឹកនាំដោយ ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យវឌ្ឍនភាព ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតក្នុងវិស័យកសិកម្ម ដែលទើបដាក់ដំណើរការជាផ្លូវការ និង ដើម្បីពិនិត្យលទ្ធភាពបញ្ចូលសេវាជាច្រើនទៀត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទទៅក្នុងប្រព័ន្ធថ្មីនេះ |
| 19/11/24 | កិច្ចប្រជុំលើកទី ២ របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច |
| 18/11/24 | កិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្ម ដើម្បីបង្ហាញ និង ចែករំលែកនូវបទពិសោធន៍ផ្ទាល់លើការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Single Portal) |



## កិច្ចប្រជុំពិភាក្សាស្ដីពីបញ្ហាប្រឈម និង ដំណោះស្រាយ ចំពោះការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន







# ព្រឹត្តិការណ៍សំខាន់ៗ

## កិច្ចប្រជុំពិភាក្សាស្ដីពីបញ្ហាប្រឈម និង ដំណោះស្រាយ ចំពោះការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន













## សិក្ខាសាលាផ្សព្វផ្សាយ និង វគ្គបណ្តុះបណ្តាល












# ព្រឹត្តិការណ៍សំខាន់ៗ

## សិក្ខាសាលាផ្សព្វផ្សាយ និង វគ្គបណ្តុះបណ្តាល













# ព្រឹត្តិការណ៍សំខាន់ៗ

## សិក្ខាសាលាផ្សព្វផ្សាយ និង វគ្គបណ្តុះបណ្តាល












## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់៖


081 888 296

www.registrationservices.gov.kh

registrationservices@mef.gov.kh

Online Business Regsitraion Service


## សហការជាមួយ